ព្រះរាជាណាចក្រកម្ពុជា

# មេរៀនសង្ខេប

# ទស្សនវិជ្ជា



ថ្នាក់ទី ១១

ឆង ប៊ុនហេង

ទិ. ត្រាះ យុគន្ធរ

ស្របតាមកម្មវិធីសិក្សាថ្មី

០៨ឋ
១១.៤០

www.budinst.gov.kh www.elibraryofcambodia.org

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥000ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្លៅ យុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥000ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីហ្ស៊ូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

០៨៥ ១១.៤០

# អារម្ភកថា

ដើម្បីឆ្លើយតបតាមសេចក្ដីត្រូវការរបស់អស់លោក សាស្ត្រាចារ្យមួយចំនួនក្នុងការខ្វះខាតឯកសារបង្រៀននូវមុខវិជ្ជាប្រវត្តិទស្សនវិជ្ជា សកល-លោកនេះ និងដើម្បីបំពេញបំណងប្អូនៗសិស្សានុសិស្ស ដែលកំពុងចង់ចេះចង់ដឹងនឹងស្វែងយល់អំពីប្រវត្តិទស្សនវិជ្ជានេះអោយបានច្បាស់លាស់ ក្នុងគោលដៅឈានចាប់យកនៅមុខវិជ្ជាទស្សនវិជ្ជាទូទៅនៅថ្នាក់ទីបញ្ចប់ខាងមុខនេះ ។ ទោះបីជាមានកាតព្វកិច្ចមមាញឹក និង ក្នុងជីវភាពយ៉ាងណាក៏ដោយក៏ខ្ញុំបាទ នៅតែខិតខំព្យាយាមចងក្រងសៀវភៅប្រវត្តិទស្សនវិជ្ជាសាកលនេះឡើងដែលសមស្របតាមទិសដៅនៃការណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡា ។

ខ្លឹមសារនៃសៀវភៅនេះ ខ្ញុំបាទដកស្រង់ចេញពីឯកសារពិគ្រោះមួយចំនួន ដូចជា

- មហាទស្សនវិទូនិងទស្សនវិជ្ជាក្នុងលោករបស់លោកសុខ សុត្ថាល
- ទស្សនវិជ្ជាខុងជឺរំលាយមហាកំពែងចិនរបស់លោកសុខ សុត្ថាល
- ទស្សនវិទូ និង ទស្សនវិជ្ជាអារ៉ាប់របស់លោក
- សូក្រាត ដោយរស់ចន្ទ្រាបុត្រ
- ប្រជុំទស្សនៈវិទូខ្លះៗ ដោយសរសារុន

BUDDHIST INSTITUTE LIBRARY
www.budinst.gov.kh www.elibraryofcambodia.org
៣៩៥៤/៥៨

www.budinst.gov.kh www.elibraryofcambodia.org

- ប្រវត្តទស្សនវិជ្ជាបញ្ចឹមប្រទេសរបស់លោក ឆយ យីយាង
- អរិយធម៌ខ្មែរ ដោយអ្នកស្រី ត្រឹង-ងា

ខ្ញុំបាទរង់ចាំទទួលការរិះគន់ដោយរីករាយក្នុងវ័យស្ថាបនារបស់អស់លោកជាបញ្ញាវន្តទាំងអស់ ។

ភ្នំពេញ, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៥

អ្នករៀបរៀង

លោក **នខ ម៉ុនឃាខ**

សាស្ត្រាចារ្យផ្នែកទស្សនះវិជ្ជា

វិទ្យាល័យ **ព្រះយុគន្ធរ**

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

**មេរៀនទី១:**

# ពិតាករ

## PYTHAGORE

**៥៧២-៥០០ មុន គ.ស**

ពិតាករជាទស្សនវិទូ និង គណិតវិទូក្រិចល្បីល្បាញម្នាក់ គាត់ជាអ្នកបង្កើតពាក្យ « ទស្សនវិជ្ជា» ដែលភាសាក្រិចហៅថា « ហ្វីឡូសូហ្វីយ៉ា» អោយប្រើមុនគេនៅសតវត្សទី៦ មុនគ. ស. មានន័យថា «ស្នេហាគតិវិញ្ញូ» ។

**-ទស្សនទិដ្ឋារបស់ពិតាករ**

ពិតាករមានទស្សនៈថា «ចំនួនជាអ្នកដឹកនាំពិភពលោក » ។ នៅក្នុងគំនិតរបសលោកពិតាករ គំនិតនេះមានលក្ខណៈអាថ៌កំបាំងជាងលក្ខណៈស្ប៉ះដោយលោកពិតាករនិងក្រុមសិស្សរបស់លោកយល់ថា : សារជាតិនៃរាល់វត្ថុបានស្តែងឡើងនៅក្នុងចំនួន ។ ចំនួនបានបង្កើតពិភពលោក និងបង្កើតសណ្តាប់ធ្នាប់ នៃសង្គម ។ ឯមនុស្សក៏កើតឡើងមកពីចំនួនសាច់ផ្សំនឹងចំនួនឆ្អឹងចំនួនសសៃផ្សំនឹងចំនួនឈាម ។

មនុស្សស្លាប់ទៅហើយកើតវិញពោលគឺ គេជឿថា : ព្រលឹងជាធាតុអមតៈ ។ ពេលព្រលឹងស្ថិតក្នុងសរីរៈព្រលឹងមានលក្ខណៈដូចជាជាប់គុកនៅក្នុងសរីរៈ ពេលដែលមនុស្សស្លាប់ទៅទើបព្រលឹងមានសេរីភាពអាចចេញពីសារីរៈបាន ។

www.budinst.gov.kh www.elibraryofcambodia.org

- ចំនួនគីឌីម អ្វីៗដែលមានចំនួនទើបប្រកបដោយសច្ចភាព

- ភារៈសំខាន់ជាងគេគឺ ភ្លើងដែលជាប្រភពនៃពុទ្ធិ ហើយដែលពិតាករដាក់តំណាងលេខ«១» ឯតាខ្មែរ វិញយល់ថា ទឹកសំខាន់ជាង ចំណែកព្រះពុទ្ធយល់ថា : ភារៈសំខាន់ជាងគេគឺមហាធាតុភូតទាំង៤មានៈ ទឹក, ដី, ភ្លើង, ខ្យល់។ ពិតាករបានតំណាងស្ត្រីឬសត្វញី ដោយលេខ២ ឯលេខ ៣ តំណាងប្រុស ឬសត្វឈ្មោលដែលមានកំលាំងជាស្រី ។ លេខ៤តំណាងអោយយុត្តិធម៌ ។ ឯលេខ៥តំណាងដោយអាពាហ៍ពិពាហ៍គឺមានន័យថា : «២បូកនិង៣» ឯលេខ ៧ តំណាងមនុស្សឥតបានការ និងលេខ ១០ តំណាងអោយអទិទេព ។

**សិលធម៌របស់ពិតាករ**

ពិតាករជាជនដែលប្រកបដោយចរិយាសម្បត្តិនិងគុណធម៌ល្អប្រពៃ។ សិលធម៌ដែលពិតាករបានចែក គឺ :

- គោរព ( អាទិទេព- វីរជន - ឪពុកម្តាយ )
- មនុស្សទាំងអស់ជាបងប្អូន .
- តាំងជាម្ចាស់ចិត្តរបស់ខ្លួន
- ស្រលាញ់យុត្តិធម៌ - អត់ធ្មត់ - អតធន់ - ខន្តី - ព្យាយាម
- មានទ្រព្យសម្បត្តិ ល្មមតែរស់បានហើយ
- អំពើដែលធ្វើទៅហើយ ត្រូវរំលឹកឡើងវិញដើម្បីពិចារណារកហេតុផលខុសនឹងត្រូវ ។

www.budinst.gov.kh www.elibraryofcambodia.org

# សូក្រាត

## SOCRATE

៤៦៩-៣៩៩ មុន គ.ស

សូក្រាតជាទស្សនវិទូដ៏ល្បីល្បាញ ខ្ទរខ្ទាររន្ទឺពាសពេញពិភពលោក។ សូក្រាតជាបិតានៃទស្សនវិជ្ជា ។ សូក្រាតកើតនៅឆ្នាំ ៤៦៩ មុន គ. សជិតក្រុងអាតែននៃប្រទេសក្រិចគឺកើតនៅក្រោយសង្គ្រាមនៅ សាឡាមីន ១០ឆ្នាំ ។ បិតាលោកឈ្មោះ សូប្រូនីស៍ ជាជាងចំលាក់នៅក្រុងអាតែន មាតាឈ្មោះ ហ្វេណារែត ជាឆ្មបជួយសង្គ្រោះជីវិតមនុស្សមិនរើសមុខ ។ ដូច្នេះហើយបានសូក្រាតតែងនិយាយថា : «ម្តាយខ្ញុំជាឆ្មបសំរាលកូន ឯខ្ញុំជាឆ្មបសំរាយគំនិត»។

តាមឯកសាររបស់អារីស្តូ បានបញ្ជាក់ថា សូក្រាតមានភរិយាឈ្មោះ សង់ទីប និងកូនពានាក់ ។ កូនរបស់សូក្រាតជាជនសាមញ្ញ ខាងផ្លូវបញ្ញា និងគំនិត គ្មានទេពកោសល្យដូចជាឪពុកឡើយ ។ សូក្រាតជាយុវជនដ៏ឆ្នើមឯកម្នាក់ គាត់ចូលបំរើប្រយុទ្ធក្នុងឋានៈជាទាហាននៃកងពលថ្មើរជើង នៅសមរភូមិជាច្រើនដូចជា : នៅស្រុកសាមូស-នៅទីប៉ូដេ -នៅដេលីយ៉ុង... ជាដើម ។

សូក្រាតមានវិធីបង្រៀនពីរយ៉ាងគឺ : សិល្បៈបង្កើតគំនិតនិងការចំអក ។


www.budinst.gov.kh www.elibraryofcambodia.org

សូក្រាតប្រើវិធីបង្កើតគំនិត ចំពោះមនុស្សសាមញ្ញដែលមិនចេះអួតអាងហើយដឹងថាខ្លួនគ្មានចេះអ្វីសោះ ។ សូក្រាតប្រើវិធីចំអក ចំពោះពួកសូហ្វីស (ពួកទស្សនវិជ្ជាមួយក្រុមដែលប្រឆាំង និងទស្សនវិជ្ជារបស់សូក្រាត ) ដែលជាអ្នកអួតអាងមានជំនឿថា ខ្លួនមានចំណេះសកល ។ ឃ្លាចំបងរបស់សូក្រាតស្តីពីទស្សនវិជ្ជាគឺ «ខ្ញុំដឹងតែមួយមុខគត់គឺ គ្មានចេះអ្វីសោះ» ។

សូក្រាតជាមនុស្សស្រលាញ់យុត្តិធម៌ គាត់ការពារយុត្តិធម៌ ។ សូក្រាតត្រូវជាប់ពិរុទ្ធពីបទប្រមាថមើលងាយសាសនានៅឆ្នាំ ៣៩៩ ។គាត់ត្រូវតុលាការវិនិច្ឆ័យទោសប្រហារជីវិត ។ ក្នុងរយៈ ៣០ ថ្ងៃក្នុងពន្ធនាគារ សូក្រាតគ្មានទុក្ខព្រួយឡើយ ។ ផ្ទុយទៅវិញគាត់គិតតែប្រឡូលអារម្មណ៍ អោយមូលទៅលើទស្សនវិជ្ជា ។ ពេលប្រហារជីវិតសូក្រាតបានជ្រើសរើសនូវវិធីផឹកថ្នាំពុលសំលាប់ខ្លួនជាជាងអោយគេព្យួរក ។ ប្រជាជនទាំងអស់នៅក្រុងអាថែននិងសិស្សរបស់គាត់ បានថ្កោលទោសចំពោះតុលាការក្រុងអាថែន ដែលបានកាត់ក្តីចំពោះរូបសូក្រាតដោយអយុត្តិធម៌ ។

## ទស្សនវិជ្ជារបស់សូក្រាត

ទស្សនវិជ្ជារបស់សូក្រាតច្រើនអប់រំបែប លិសវិជ្ជា :

- ត្រូវយល់ពីដំណើរប្រព្រឹត្តទៅនៃធម្មជាតិ
- ត្រូវយល់អ្វីដែលនៅជិតយើង មុននឹងយល់អ្វីដែលឆ្ងាយពីយើង
- ត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង

www.budinst.gov.kh www.elibraryofcambodia.org

- ត្រូវដុសខាត់ព្រលឹងអោយបានប្រសើរជាងដុសខាត់សរីរៈ ។

- ត្រូវនិយមប្រើពាក្យថា «ខ្ញុំមិនចេះអ្វីសោះ» ។

- ត្រូវជជែកគ្នាដើម្បីរកការពិតព្រោះការជជែកជាវិធីបង្កើតគំនិត។ លទ្ធផលដែលល្អជាលទ្ធផលដែលបានទទួលការរិះគន់រួចហើយ ។

- សូក្រាតពោថា : ពុំមានណាម្នាក់ កាចដោយចេតនាទេ ។ មនុស្សម្នាក់ៗសុទ្ធតែមានបំណងល្អ តែបើប្រែជាអាក្រកវិញគឺ ពិតជាមានបុព្វហេតុដូចជា បុព្វហេតុផ្ទាល់ខ្លួនឬក្រៅខ្លួន ។ តែចំពោះប្លាតុង វិញយល់ថា មនុស្សកើតមកមានអកប្បកិរិយាខុសៗគ្នា ខ្លះល្អ ខ្លះអាក្រក់ ខ្លះស្លូត ខ្លះកាច តាមនិស្ស័យធម្មជាតិ ។

- ក្នុងគំលៃសីលធម៌សូក្រាតចេញមុខប្រឆាំងនឹងពួកសូហ្វីស ដែលចូលចិត្តយកពាក្យសំដី ទៅប្រើផ្លូវខុស ហើយធ្វើអកប្បកិរិយាដូចជាអ្នកចេះដឹងច្រើន ។

សូក្រាតជាមនុស្សថ្មី ចំឡែកដែលបានក្លាយជាទស្សនវិទូគំរូមួយរូបសំរាប់ជំនាន់ក្រោយ ។ គេតែងនិយាយថា « សូក្រាតជាបុរសនៃក្រុងអាតែនដែលមានរូបអាក្រក់ ហើយល្អជាងគេបំផុត » ។

www.budinst.gov.kh www.elibraryofcambodia.org

# ដេម៉ូក្រីត

## DÉMOCRIT

### ៤៦០-៣៧០ មុន គ.ស

ដេម៉ូក្រីត ជាទស្សនវិទូ រូបធាតុនិយមក្រិចបូរាណដ៏ល្បីមួយរូបគាត់ស្ថិតនៅក្នុងវណ្ណៈនៃស្រទាប់ម្ចាស់ទាសករប្រជាធិបតេយ្យ ។ គាត់ជាអ្នកចង់តែប្រែសង្គម ដោយបើកសិទ្ធិសេរីភាពអោយប្រជាពលករ ។

**+ផ្នែកជីវិតឧបត្ថម្ភ**

ដេម៉ូក្រីតជាអ្នកអានជីវិតវប្បធម៌ខ្ពស់ផ្នែកអក្សរសាស្ត្រ គាត់ជាអ្នកស្រាវជ្រាវទស្សនវិជ្ជា ឧត្តនិយម- គណិតវិទ្យា- រូបវិទ្យា- ជីវវិទ្យា និង សិល្បវិជ្ជា ។ គាត់ជាមនុស្សឈ្លាសវៃ អាចសំរបសំរួលហេតុការការបានគ្រប់យ៉ាង ។ លេនីន ឬ អង់ហ្គែលក្ដី បានចាត់ទុកដេម៉ូក្រីតជាមនុស្សសព្វវចនានុក្រម ព្រោះគាត់ចេះសព្វមុខវិជ្ជា ។

**+ទស្សនវិជ្ជារបស់ដេម៉ូក្រីត**

ដេម៉ូក្រីតយល់ថា ៖ ក្នុងពិភពលោកភាវៈ កើតពីវត្ថុធាតុអ្វីមួយ៉ាងល្អិតបំបែកពុំបាន មិនប្រែប្រួលនិងស្ថិតស្ថេររហូត ។ គាត់បានអោយឈ្មោះថា «អាតូម» ហើយបង្កើតបានជាទ្រឹស្ដីអាតូមនិយម ។ អាតូមបង្កើតអោយមានៈ



www.budinst.gov.kh www.elibraryofcambodia.org

ភ្លៀង- ខ្យល់- ព្យុះ -កំដៅ -ត្រជាក់ -ក្លិន និង អ្វីៗទាំងអស់រហូតដល់ព្រះអាទិត្យ ព្រះច័ន្ទ ឯព្រលឹងក៏កើតពីអាតូមដែរ ។ អាតូមជាប្រភពនៃពុទ្ធិសព្វយ៉ាង ។

-ភពដែលមានជីវិតរស់នៅបាន គឺមកពីភពនេះមានអង្គធាតុម្យ៉ាងគឺអង្គធាតុសរីរាង្គ ឯភពដែលមិនទាន់មានជីវិតគឺមកពីគ្មានធាតុសរីរាង្គ ។ ការកើតនេះមកពីចលនានៃអាតូមដែលជះឥទ្ធិពលលើគ្នា ។

-ចំពោះបញ្ហាព្រលឹង :ជាបញ្ហាធម្មជាតិ គ្មានកំលាំងអទិទេព ឬ អាថិកំបាំងណាបង្កើតទេ គឺ វាកើតពីការតួបផ្សំនៃអាតូម ។ ញាណគ្មានកំលាំងអភិធម្មជាតិបង្កើតទេ ។ រូបកាយកើតហើយទើបញ្ញា កើតក្រោយ ។ ពេលរាងកាយបែកខ្ទេចអាតូមក៏បែកខ្ចាយ ញាណឬប្រលឹងក៏អស់ទៅដែរ ។

ដេម៉ូគ្រីតចែកពុទ្ធិជាពីរបែប : ពុទ្ធិងងឹតនិងពុទ្ធិពិត ។

-ពុទ្ធិងងឹត : ជាពុទ្ធិចាប់ផ្តើមដឹងពីឥន្ទ្រិយារម្មណ៍គឺដឹងដោយសារអង្គវិញ្ញាណ

-ពុទ្ធិពិត : ជាពុទ្ធិវិចារ (ការពិចារណា )

ដេម៉ូគ្រីតជាមនុស្ស សុទិដ្ឋិនិយម គាត់និយមថា :

-មនុស្សត្រូវចេះសប្បាយ និង ស្វែងរកការសប្បាយ ។

-សុខចិត្តអោយមានសំលាញ់តិច មិត្តសំលាញ់ដែលកើតដោយសារ

www.budinst.gov.kh www.elibraryofcambodia.org

ការជ្រើសរើសដោយម៉ក់ចត់ហើយគួររើសអ្នកណាដែលមានគំនិតដូចអ្នកដែរ ។

- ត្រូវចៀសវាងជំពោះគ្រប់បែបយ៉ាង ពិសេសជាមួយអ្នកនៅក្បែរខ្លួនយើង ។

- ត្រូវគោរពវង្វាក់៣ (មតិស្រប មតិផ្ទុយ មតិសំយោគ ) ដែលជាច្បាប់ក៏ធំទ្រទ្រង់ដំណើរពិភពលោក ។

- ដេម៉ូគ្រិត ជាអ្នករូបធាតុនិយម តែមិនទាន់ផាច់ខាតគាត់នៅមានទស្សនៈជឿរលឿនក្នុងការវិភាគដំណើរប្រវត្តិសាស្រ្តសង្គម ។

www.budinst.gov.kh www.elibraryofcambodia.org

# ប្លាតុង

## PLATON

**៤២៨ - ៣៤៧ មុន គ . ស**

ប្លាតុងជាសិស្សជំនិតរបស់សូក្រាត ។ ប្លាតុងកើតនៅអាតែន Athéne ប៉ុន្តែអ្នកខ្លះថាលោកកើតនៅអេហ្ស៊ុន (Egine) ។ ឪពុកលោកជាម្ចាស់ទាសករនៅអេហ្ស៊ីន ដែលមានឈ្មោះថា អារីស្តុង Ariston ក្នុងត្រកូលព្រះរាជវង្សកូដ្រ (Codre) នៅអាតែន ។ ម្តាយឈ្មោះ បើរិស៊ីយ៉ូន ដែលកើតក្នុងគ្រួសារអភិជន ។ ម្តាយលោកជាប់ត្រកូលជាអ្នកច្បាប់សូឡុង ។ ប្លាតុងកើតក្នុងគ្រួសារ អភិជនដ៏ខ្ពង់ខ្ពស់ ។ គាត់មិនដែលវាយឫកឬមើលងាយអ្នកមានសមត្ថភាពទាបជាងគាត់ទេ ។ តាមការស្រាវជ្រាវ គេដឹងថា ប្លាតុងមានគ្រូ៣នាក់ឈ្មោះ ក្រទីល -អេរ៉ាក្លិត- និងសូក្រាត ។ ប្លាតុងជាអត្តពលករដ៏ចំណានអង់អាចល្បីល្បាញក្នុងសម័យនោះផង ។

ប្លាតុងចូលចិត្តធ្វើដំណើរនិងធ្វើនយោបាយ ព្រមទាំងជាអ្នកផ្តើមគំនិតបង្កើតសភានៅឆ្នាំ ៣៨៧ មុន គ. ស ។ ប្លាតុងនិយមប្រើវិធីបង្កើតគំនិតនិងវិធីចំអក ដូចសូក្រាតដែរ ។ ក្រោយពេលសូក្រាតស្លាប់ទៅ តុលាការក្រុងអាតែនមានបំណងចង់ប្រហារជីវិតប្លាតុងទៀត ទើបប្លាតុងរត់ភៀសខ្លួន-

www.budinst.gov.kh www.elibraryofcambodia.org

ចេញពីក្រុងអាតែន ។ ដំណើរផ្សងព្រេងរបស់ប្លាតុងនៅភូមិភាគខាងជើងនៃប្រទេសអាហ្វ្រិក ប្លាតុងបានជួបជាមួយនឹងទស្សនវិទូជាច្រើន ជាហេតុញ៉ាំងគាត់អោយកាន់តែពង្រីកពុទ្ធិបានថ្មីៗថែមទៀត ហើយប្លែកៗផង ។ ខ្សែជីវិតរបស់ប្លាតុងក៏កំសត់មិនខុសពីសូក្រាតជាគ្រូបន្ទាន់ដែរ ។ ប្លាតុងត្រូវស្តេចដីនីស៍នៃទីក្រុងស៊ីរ៉ាគូស ចាប់ដាក់គុកងងឹតដោយអយុត្តិធម៌ ។ ដោយសារបានជំនួយឧត្តមពីសិស្សរបស់គាត់ ប្លាតុងក៏បានវិលត្រលប់មកទីក្រុងអាតែនវិញនៅឆ្នាំនោះឆ្នាំ ៣៨៧ មុន គ.ស ។ ដោយសារគាត់មានមរតកប្រចាំត្រកូលនិងមានជំនួយខ្លះពីសិស្សឈ្មោះ អានីសេរីស នោះផង ប្លាតុងបានសំរេចចិត្តបើកសាលាព្រឹទ្ធសភារបស់លោកប្លាតុង ។ គេសង្កេតឃើញមានស្ត្រីជាច្រើនបានចូលរួមសិក្សាផងដែរ ។ ក្នុងសម័យនោះមានការលើកតំកើងនិងផ្តល់សិទ្ធិអោយស្ត្រីភេទ ។ ប្លាតុងពិតជាមនុស្សម្នាក់ដែលបានអោយតំលៃទៅលើសមភាពនៃភេទ ។ នេះគាត់ទុកជាការវិវត្តយ៉ាងធំ នៃគំនិតមនុស្សគ្រាជំនាន់នោះ ។ ប្លាតុងនិយាយថា «ស្ត្រីជាពាក់កណ្តាលមនុស្ស ហើយជាម្ចាស់របស់ពិភពលោកទាំងមូល... ប្រសិនបើគេមិនអោយសិទ្ធិសេរីភាពហើយបើមិនផ្តល់វិជ្ជាទាំងពួងដល់ស្ត្រីទេគឺ គាត់ទុកជាការអកតញ្ញូមួយយ៉ាងធំ ... នរណាដែលប្រកាន់ស្ត្រីភេទអ្នកនោះពិតជាមើលងាយអ្វីៗទាំងអស់ ដែលកើតមានលើផែនដីនេះ ។

**ទស្សនវិជ្ជារបស់ប្លាតុង** ✓

- ក្នុងទស្សនវិជ្ជារបស់លោក លោកបានបង្កើត ។


www.budinst.gov.kh www.elibraryofcambodia.org

- ទ្រឹស្តីអំពីឥន្ទ្រិយ៍ភពនិងទ្រឹស្តីអំពីមនោភព តែគាត់ពុំបានផ្តាច់ឥន្ទ្រិយភពចេញពីមនោភពទេ ។

- ទ្រឹស្តីអនុស្សាវរីយ៍នោះគឺការរំលឹកឡើងវិញដែលយើងបានធ្វើរួចហើយ ដើម្បីវិនិច្ឆ័យថា : អំពើណាជាអំពើល្អ អំពើណាជាអំពើអាក្រក់ ។

- ទ្រឹស្តីអំពីអមតៈភាពនៃព្រលឹង ។

- ទស្សនៈវិធីមួយគឺបដិសំយោគ ដើម្បីជជែកឆ្លើយឆ្លងគ្នាស្វែងរកពុទ្ធិ តាមទ្រឹស្តីអនុស្សាវរនោះ ប្លាតុងយល់ថា បុគ្គលជាការផ្សំរវាងសរីរៈគួបផ្សំនឹងព្រលឹង សរីរៈជាសំខតធាតុ (ទឹក- ដី- ភ្លើង- ខ្យល់ ) ឯព្រលឹងជាសូល ។

ប្លាតុងយល់ថា ការសិក្សាទស្សនវិជ្ជាជាការធ្វើដំណើរឆ្ពោះទៅរកសច្ចៈ ។ វិជ្ជាចរិយាសាស្ត្ររបស់ប្លាតុងគឺតែងអោយតំលៃទៅលើគុណធម៌ ។ ប្លាតុងចង់អោយសង្គមមានយុត្តិធម៌និងសមភាពរវាងគ្នានឹងគ្នា ) ស្នាដៃរបស់គាត់គឺ «សាធារណរដ្ឋ » ដែលមានវគ្គខ្លះចែងថា : ត្រូវក្លាហានជានិច្ចនៅចំពោះមុខសត្រូវរបស់ខ្លួន ។ ត្រូវរក្សាទឹកមុខអោយបានធម្មតា នៅពេលកើតមាន ឬជួបឧបសគ្គទាំងឡាយទូទៅ ។

- ត្រូវជំនះដឹងមហិច្ឆតារបស់ខ្លួនឯង ពោលគឺកុំលោភលន់ ។

- ត្រូវកុំខឹងច្រើនព្រោះការខឹងជាមាតាសំរាប់ធ្វើអោយយើងធ្លាក់ចូលក្នុងភាពកំណាច ។

www.budinst.gov.kh www.elibraryofcambodia.org

## ទ្រឹស្តីគំនិតរបស់ឡុក

ពុទ្ធិសត្វៈ ទាំងអស់បង្កើតឡើងវិញនូវសារព័ន នៃគំនិតដែលជាគំរូងាយយល់នៃគ្រប់ទំនាក់ទំនងខាងក្រោម ៖ អំពីការប្រៀបធៀបអាវរបស់ពីយែរ និងអាវរបស់ហ្សាកដែល តូចជាងពីយែរ និងអាវប៉ូលដែលធំជាងពីយែរ ខ្ញុំសន្និដ្ឋានថា គំនិត «ទំហំ» គ្រាន់តែជាគំនិតធៀបប៉ុណ្ណោះ ។ តើបាន់គំនិត «ទំហំ » នេះមកពីណា ? ឡុកពោលថា «គំនិត» «ទំហំ» នេះមិនមែនស្ថិតនៅក្នុងពិភពវេទយិតទេ តែវាគ្រាន់តែអាចអត្ថិភាពក្នុងគំនិតប៉ុណ្ណោះ ។

Paul ធំជាង Pierre ធំជាង Jaques

www.budinst.gov.kh www.elibraryofcambodia.org

# អារីស្តូត
## ARISTOTE
### ៣៨៤ - ៣២២ មុន គ.ស

អារីស្តូតជាជនជាតិក្រិច កើតនៅស្តាហ្សៀ (Stagire)

ក្នុងទីរួមខេត្តកាល់ស៊ីឌីច Chalcidique ដែលលស្ថិតនៅលើមាត់សមុទ្រអេហ្ស Egée ជិតប្រទេសម៉ាសេដូន Macédoine ។ ឪពុករបស់លោកឈ្មោះនីកូម៉ាក ។ លោកជាគ្រូពេទ្យឯកទេសព្យាបាលជំងឺរបស់ព្រះបាទអាមីនតាសទី២ ដែលសោយរាជ្យនៅក្នុងព្រះរាជាណាចក្រ ម៉ាសេដូន ។ អាមីនតាសជាព្រះរាជបិតារបស់ព្រះចៅហ្វីលលីព ។ អារីស្តូតបានក្លាយជាក្លាយជាគ្រូវបង្រៀននិងជាទីប្រឹក្សាផ្ទាល់ជាទីគោរពស្រឡាញ់នៃកុមារអាឡិចហ្សង់ ជាកូនស្តេចហ្វីលីព ។

អារីស្តូចបានប្រើអំណាចតាមរយៈស្តេច ដោយចេញបញ្ជាដល់អ្នកនេសាទ ព្រានប្រមាញ់អោយចាប់យកសត្វនីមួយៗ មកធ្វើគំរូដើម្បីអារីស្តូចរៀបចំសព្វវិជ្ជា ព្រោះមានសត្វច្រើនណាស់ដែលគេស្គាល់ឈ្មោះមិនអស់ ។

នៅឆ្នាំ·៣៣៥ អារីសស្តូចបានបង្កើតវិទ្យាល័យមួយនៅក្រុងអាថែនក្បែរវិហារ អាប៉ូឡូសីសេអ៊ុលដែលគេទំលាប់ហៅ លីសេអ៊ុមបារាំងហៅថា-



www.budinst.gov.kh www.elibraryofcambodia.org

លីសេ (Lycée) ។ វិធីបង្រៀននៅក្នុងវិទ្យាល័យនេះមានលក្ខណៈផ្សេងៗពីវិទ្យាល័យដទៃទៀត ដោយមានការរៀបចំអោយគ្រូបង្រៀនសិស្សនៅក្រៅថ្នាក់ច្រើនជាងនៅក្នុងថ្នាក់កិដើរបណ្តើរបង្រៀនបណ្តើរ ទស្សនិយមការសិក្សាដោយមធ្យោបាយដើរលេងបែបនេះហៅថា « បេរីប៉ាតូស » ប្រែជា «កំសាន្តសិក្សា »

## ទស្សនវិជ្ជារបស់អារីស្តូត

ដោយលោកអារីស្តូជាសាវិករបស់ប្លាតុងគោលគំនិតសំខាន់ៗខ្លះក្នុងទស្សនវិជ្ជាទាក់ទងនឹងប្លាតុង ដូចជាៈ ទ្រឹស្តីអំពីឥន្ទ្រីយ៍ភពឆ្ពោះទៅរកមនោភព ស្វែងរកកុសល ។ ទស្សនវិជ្ជាបែបនេះ ត្រូវអារីស្តូចហៅថា : ទស្សនវិជ្ជាអស្សិរូប ។

-ប្លាតុងយល់ថា : គំនិតខ្ពង់ខ្ពស់ស្ថិតនៅដាក់ចេញពីឥន្ទ្រីយ៍ភពក៏ចាប់ផ្តើមពីឥន្ទ្រីយ៍ភព ។ ចំណែកអារីស្តូចយល់ប្លែកពីប្លាតុងបន្តិច ដោយអះអាងថា មនោភពក៏ស្ថិតនៅក្នុងឥន្ទ្រីយ៍ភពដែរ ។ មានន័យថា : នៅក្នុងភារៈមួយគេអាចបំបែកគំនិតពីរយ៉ាង

- គំនិតទាំងឡាយ ដែលទាក់ទងទៅនឹងឥន្ទ្រីយ៍
- គំនិតទាំងឡាយដែលទាក់ទងទៅនឹងមនោ

ប៉ុន្តែឥន្ទ្រីយ៍និងមនោស្ថិតនៅរួមគ្នា :គ្រាន់តែគំនិតមួយបង្ហាញអ្វីដែលយើងឃើញពេលបច្ចុប្បន្ននិងគំនិតមួយទៀតមានទំនោរទៅរកអនាគត ។ អារីស្តូតបានលើកភស្តុតាងមកបញ្ជាក់ដូចជាគ្រាប់ផ្លែឈើនឹងទៅជារុក្ខជាតិ-

www.budinst.gov.kh www.elibraryofcambodia.org

នៅពេលអនាគតមនុស្សកំពុងដេកនឹងភ្ញាក់ពេលខាងមុខ ។

អារីស្តូតមានទស្សនៈថា «រូបធាតុជាបុព្វហេតុបង្កើតភាវៈផ្សេងៗ គាត់បានបង្កើតទ្រឹស្តីអំពី «រូប» និង «រាង» ។ រូបជាស្នូលដែលបង្កើតភាវៈឯរាងជាទំរង់ខាងក្រៅជាហេតុបញ្ចប់និងជាបំណងចុងក្រោយរបស់មនុស្ស ។ រាងនេះហើយជាអទិទេពតំណាងកុសលនិងសាភ័ណ ។»

គាត់បានបង្កើតទ្រឹស្តីមួយទៀតហៅថា : ត្រីវាទនិយម ដែលមានប្រយោគ ៣គឺ ÷

- មនុស្សទាំងអស់ត្រូវតែស្លាប់ «ប្រយោគច្បង»
- សូក្រាតជាមនុស្ស «ប្រយោគរង»

ដូចនេះសូក្រាតត្រូវតែស្លាប់ យោបល់

គោលបំណងរបស់អារីស្តូតដែលបង្កើតទ្រឹស្តីត្រ័យវាទនិយមនេះ គឺចង់រក្សាឈ្មោះសូក្រាតអោយស្ថិតនៅក្នុងភាពអមតៈ ព្រោះអារីស្តូតបានជ្រើសរើសយកឈ្មោះសូក្រាតជារូបធាតុដើម និងជាប្រធាននៃទ្រឹស្តីនេះ ។ គាត់មានបំណងមិនចង់អោយសាវ័កទាំងឡាយដែលនៅជាប់ជំពាក់ផ្លូវមនោសញ្ចេតនាជាមួយសូក្រាត ស្តាយស្រណោះសូក្រាតខ្លាំងពេក ព្រោះមនុស្សម្នាក់ៗមិនអាចចៀសផុតពិសេចក្តីស្លាប់បានឡើយ ។ គ្រាន់តែមួយស្លាប់គ្មានន័យ មួយស្លាប់ក្នុងកិត្តិយស ។ ចំណែកសូក្រាតស្លាប់ក្នុងកិត្តិយសល្បីល្បាញ ។

www.budinst.gov.kh www.elibraryofcambodia.org

## សីលធម៌របស់អារីស្តូត

- សីលធម៌របស់អារីស្តូតជាគុណធម៌ផ្លូវកណ្តាលគឺ

- កុំក្លាហានពេក តែកុំកំសាកពេក ។

- កុំចង់បានពេក តែមិនត្រូវមិនរវីរវល់សោះនោះទេ ។

- កុំភ្លេចប្រយោជន៍ខ្លួន តែមិនត្រូវតាំងចិត្តជាអត្តទត្ថបុគ្គលទេ ។

- សីលធម៌របស់រដ្ឋចៀសវាងដាច់ខាត មិនប្រើអំណាចបង្ខិតបង្ខំនូវអ្វីដែលពលរដ្ឋ មិនពេញចិត្តនោះទេ ។

- កើតមកជាមនុស្សត្រូវចេះច្រើនបោកាយ មិនចេះតិសត្ថ ។

- ត្រូវស្រលាញ់មនុស្សជាតិ គាំទ្រអ្នកចេះដឹង ដែលចាត់ទុកជាបណ្ឌិត ទោះបីមានកំហុសម្តេចម្តា ច្បាប់រដ្ឋត្រូវចៀសវាងការប្រហារជីវិតមនុស្ស ។ អារីស្តូតរំលឹកពីអនុស្សាវរីយ៍ ជួរចដ់ពេលប្រហាជីវិតសូក្រាត ។ អារីស្តូចជាទស្សនវិទូមួយរូបមានកិត្តិនាមល្បីល្បាញណាស សូម្បីបាតុងដែលជាគ្រូក៏វិនិច្ឆ័យថា : អារីស្តូតជាទស្សនវិទូរបស់សច្ចធម៌ ។

www.budinst.gov.kh www.elibraryofcambodia.org

# សមណគោតម

**៦២៤-៥៤៣ មុន គ.ស**

គេតែងនាំគ្នាពោលថា ព្រះពុទ្ធជាទស្សនវិជ្ជ ។ តាមការពិតព្រះពុទ្ធសមណៈគោតមមិនត្រឹមតែជាទស្សនវិទូទេ ថែមទាំងព្រះអង្គជាសព្វញ្ញូជន គឺជាអ្នកត្រាស់ដឹងសព្វបែបយ៉ាងឥតចន្លោះគេពុំទាន់ឃើញមានអ្នកប្រាជ្ញា ក្នុងលោកណាដែលអាត្រាស់ដឹងស្មើនឹងព្រះពុទ្ធឡើយ ។ ដូច្នេះហើយបានជាលទ្ធិនៃពុទ្ធសាសនា មានអាយុយូរអង្វែងផ្ទាំងខាងសច្ចភាពមុនគេ ។

តើទស្សនវិជ្ជារបស់ព្រះអង្គមានឥទ្ធិពលនិងមានសច្ចភាពយ៉ាងដូចម្តេច ?

## ទស្សនវិជ្ជារបស់ព្រះពុទ្ធ

ព្រះពុទ្ធជាមនុស្សសាមញ្ញរស់នៅក្នុងសង្គមស្គាល់នូវជីវភាពពិតរបស់មនុស្សលោក ។ លោកបានបន្សល់ទុកនូវទ្រឹស្តីនិងទស្សនៈជាច្រើនសំរាប់អោយកូនចៅជំនាន់ក្រោយពិចារណាដើម្បីស្វែងរកសុខៈក្នុងជីវិត ។

ទស្សនៈវិជ្ជាក្នុងពុទ្ធសាសនា ចែកជាទស្សនៈ ៣យ៉ាងគឺ :

- ទស្សនៈ អរិយសច្ច, ទស្សនៈកម្មផល, ទស្សនៈបដិច្ចៈសមប្បាទ



www.budinst.gov.kh www.elibraryofcambodia.org

## ៣) . ទ្រឹស្តីបដិច្ចសមុប្បាទ

ទ្រឹស្តីនេះបញ្ជាក់ថា «បើនេះមាននោះក៏មាន » «បើនេះរលត់នោះក៏រលត់» ។ ដូចនេះពុំមានភារៈណាកើតឡើងដាច់តែឯង ដោយគ្មានហេតុបច្ច័យទាក់ទងគ្នានោះទេ ។ ទ្រឹស្តីនេះសង្កត់ធ្ងន់លើ « អវិជ្ជា » កាលណាមានអវិជ្ជាអាចនាំទៅដល់មរណៈ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ព្យាយាមធ្វើសមាធិកម្មក្នុងព្រៃរហោស្ថានមិនគិតពីកាយពលទ្រូឌទ្រោម ដើម្បីពិចារណារកឫសគល់នៃបាតុភូតសង្គមនឹងពិសេចក្តីសុខ ទុក្ខរបស់មនុស្សសត្វព្រះអង្គបានស្វែងរកប្រភពនៃទុក្ខឃើញ ហើយបានបង្កើតជាទ្រឹស្តីនិងពុទ្ធោវាទ ប្រៀបប្រដៅយើងថា :

- អ្នកទាំងឡាយចូរកាត់ផ្តាច់នូវគ្រឿងស្រវឹងក្នុងលោកនេះហើយត្រូវបន្ទោរបង់អោយដាច់ស្រឡះពីសេចក្តីសោកនោះទើបអាចដោះខ្លួន អោយរួចចាកសង្សារជាគ្រឿងអស់ទៅនៃសេចក្តី ទាំងពួងបាន ។

- របស់ទាំងអស់ ទាំងពួងនៅលើលោកនេះសុទ្ធតែអន្តរកាលទាំងអស់

- កាលណាមនុស្សធ្វើអំពើអាក្រក់ ឈ្មោះថា មនុស្សនោះបង្កាត់ភ្លើងនរកហើយត្រូវឆេះខ្លួនដោយភ្លើងរបស់ខ្លួនឯង ។

- គ្មានសត្រូវណាខ្លាំងពូកែជាងរោគទេ ?

- គ្មានរោគណាខ្លាំងពូកែជាងការស្រេកឃ្លាន

- បុគ្គលឥតទីពឹងពាក់តែងនៅជាទុក្ខ ។

www.budinst.gov.kh  www.elibraryofcambodia.org

នៅពេលព្រះអង្គជិតចូលបរិនិព្វានព្រះអង្គផ្ដែផ្ដាំភិក្ខុទាំងឡាយថាៈ ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគតប្រាប់អ្នកថា អ្វីដែលកើតឡើងហើយមាន ហើយផ្តុំផ្សំហើយ តែងមានធម៌ភពរលត់ជាធម្មតា អ្នកទាំងឡាយចូរញុំាង ប្រយោជន៍អោយសំរេចដោយកិរិយាមិនធ្វេសប្រហែសចុះ » ។

www.budinst.gov.kh www.elibraryofcambodia.org

មេរៀនទី៧

# ខុងជឺ

**៥៥១ - ៤៧៩ មុន គ.ស**

ខុងជឺជាមហាទស្សនវិទូចិនមួយរូបដ៏ល្បីល្បាញមានកិត្តិនាមស្មើនឹងសូក្រាតនៅប្រទេសក្រិច ។

តាមពិតលោកឈ្មោះ ជី ត្រកូលស្ថិតនៅសម្ព័ន្ធឡូ ។ ត្រកូលរាជវង្សរបស់លោកជាអភិជន ហើយបើតាមការស្រាវជ្រាវវង្សត្រកូលនេះមានពូជធារតមកពីរាជវង្ស «ចាង» ដែលជាសន្តតិវង្សមួយគ្រប់គ្រងប្រទេសចិនសម័យរជ្ជកាលចូវ ។ ដោយសារសង្គ្រាមរ៉ាយលុកពីកុលសម្ព័ន្ធ «ចូវ» ស្ថិតនៅពាយ័ព្យ ទន្លេលឿងរាជវង្សចាង ក៏ត្រូវរលាយបាត់បង់ក្នុងសង្គ្រាម ។ ឯសមាជិកត្រកូលដែលរួចពីស្លាប់ក៏បន្ទំខ្លួន ក្នុងកុលសម្ព័ន្ធ «ឡូ» ។

## កំណើតខុងជឺ

ខុងជឺកើតនៅឆ្នាំ ៥៥១ មុន គ.ស ក្នុងទីរហោដ្ឋាននៃក្រុងមេរ៉ាងថ្មភ្នំ ភូមិនៃស្រុកចាន់តុង ក្បែរវាលពិធីបុណ្យរបស់លោកកោសរ៉ែនៃសន្តតិវង្សឡូ ។ នៅពេលចាប់កំណើតនិងថ្ងៃកើតរបស់ខុងជឺមានអព្ភូតហេតុចំលែកគួរអោយកត់សំគាល់គឺ ៖ ព្រះភ្លើង រន្ទះ រញ្ជួយភ្នំ ។ ខុងជឺកំព្រាឪពុកតាំងពីអាយុ៣ឆ្នាំ ហើយរកាន់ចិត្តសប្បុរសធម៌ តាំងពីក្មេងតែគាត់រស់ក្នុងទីទុរគ៌ត ។ ព្រះបាទ-

www.budinst.gov.kh www.elibraryofcambodia.org

អាយុ ២០ឆ្នាំ គាត់បានរៀបការជាមួយស្រីជាតិម៉ុងហ្គោលម្នាក់ដែលមានកូនប្រុសឈ្មោះលី ។ ដោយការខិតខំសិក្សាស្រាវជ្រាវខុងបានក្លាយជាគ្រូម្នាក់ដែលចេះដឹងសព្វមុខវិជ្ជា ពិសេសខាងវិជ្ជាពេទ្យ ខុង ចេះទស្សន៍ទាយ ខុងជាអ្នកបង្ហាត់អោយប្រជាជនចិនចេះសែនព្រេន ជូនតាតាមបេក្ខណៈថ្មី ខុងក្លាយជាអាចារ្យពេលអពាហ៍ពិពាហ៍ ឬ ក្នុងពិធីបុណ្យផ្សេងៗ ។ កិត្តិនាមខុងល្បីល្បាញពេញស្រុកចាន់ស៊ី ហើយពេលនោះ ទស្សនវិជ្ជារបស់ខុង ក៏ចាប់រីកដុះដាលគេនាំគ្នាប្រសិទ្ធិនាមអោយគាត់ថា : «ជូ» ប្រែថា បណ្ឌិត ចាប់ពីពេលនោះមក នៅអាយុ៤៩ឆ្នាំ ខុងត្រូវបានមហាក្សត្រ តែងតាំងធ្វើជាសេនាបតីធំម្នាក់ក្នុងវាំង ។ ខុងជឺបានផ្សព្វផ្សាយទស្សនវិជ្ជារបស់គាត់គ្រប់ទិសទីពាសពេញប្រទេសចិន ក្នុងបំណងអោយប្រជាជនចិនស្គាល់ យល់នូវតំរិះរបស់ខ្លួន និងចង់ប្រែតែត្រូវមហាក្សត្រ ល្ងង់ទាស់ ។ ដោយវិបត្តិនយោបាយខុងបានភៀសខ្លួនពីស្រុកមួយទៅស្រុកមួយ អស់រយៈពេល១៣ឆ្នាំ ។ ខុងជឺបានវិលត្រលប់ចូលស្រុកលូវិញក្នុងជន្មាយុ៧០ឆ្នាំ ។ ខុងបានផ្សាយទស្សនវិជ្ជារបស់គាត់អស់រយៈ ១៣ឆ្នាំក្នុងស្រុកចិនទាំងមូល ព្រមទាំងបើកសាលាបង្រៀនដល់សាវ័កទៀតផង ។ ខុងមិនគ្រាន់តែជាគ្រូបង្ហាត់ក្បួនខាតផ្សេងៗប៉ុណ្ណោះទេ តែមទាំងជាអ្នកដឹកនាំប្រជាជនអោយអនុវត្តន៍នូវទំនៀមទំលាប់ សុទិដ្ឋិផ្នែកវប្បធម៌សង្គមធម៌និងសាសនាថែមទៀត ។ ខុងបានកែប្រែនូវទំនៀមទំលាប់ចាស់អោយរីកចំរើនឡើងវិញ ។ គេសង្កេតឃើញប្រជាជនចិនចាប់ប្រើក្រដាស់ និងដក់ខ្មៅដុសថ្នាំសំរាប់សរសេរ និង ទំនៀមទំលាប់សែនផ្លូវជូនតារាល់ឆ្នាំ តាំងពី

www.budinst.gov.kh www.elibraryofcambodia.org

សម័យខុងមក ។ ក្រោយពីផ្សងព្រេង ១៣ឆ្នាំ ខុងបានវិលត្រលប់ចូលមកអាណាចក្រលូវិញ ក្នុងវ័យជរា ។ គាត់រស់បានពេញ្ញាំក្នុងសំណាក់សាវ័ក ទាំងឡាយហើយធ្វើមរណកាលក្នុងឆ្នាំ ៤៧៩ មុន គ. ស ។

## ទស្សនវិជ្ជាខុងជឺ

ខុងជឺ បានចងក្រងគម្ពីរឈ្មោះហៅថា «ពកវ៉យី » ប្រែថាសិល្បៈទាំង៦ ជាសិល្បៈសេរី មានគោលដៅស្វែងរកនូវសេរីភាពក្នុងនយោបាយ និងសេដ្ឋកិច្ច ។

## ទស្សនវិជ្ជាទាំង ៦ របស់ខុងជឺគឺ:

១- **គម្ពីរឈ្មោះយី** ចែងពីការផ្ទេរកម្មសិទ្ធិនិងផ្ទេរមកតក ។

២- **គម្ពីរឈ្មោះចេ** ជាកំណាព្យនិទានសំរាប់បំរើសោភ័ណ្ឌធម្មជាតិ

៣- **គម្ពីរឈ្មោះលី** ជាការប្រារព្ធធ្វើពិធីសែនព្រេនផ្សេងៗ

៤- **គម្ពីរឈ្មោះយ៉ើ** ចែងពីបទភ្លេង និងចំរៀងបណ្តែតអារម្មណ៍

៥- **គម្ពីរឈ្មោះឌូ** ចែកពីប្រវត្តិសាស្ត្រនិងពង្សាវតានៃប្រទេសចិន

៦- **គម្ពីរឈុស៊ាវ** ឬ **គម្ពីរនិទាឃរដូវ** សរទរដូវជាប្រវត្តិសាស្ត្រជាក់ស្តែងរបស់សន្តិវង្សលូ ។

ចំពោះគុណសម្បត្តិនៃទស្សនវិជ្ជា ខុងជឺបានអោយតំលៃទៅលើសប្បុរសធម៌- មនុស្សធម៌និងយុត្តិធម៌ ដូចមានទស្សនៈពោលថា :



www.budinst.gov.kh www.elibraryofcambodia.org

- ធ្វើគុណទៅហើយ បើគេតបមកវិញចាត់ទុកដូចជាពុំអានធ្វើគុណ

- ធ្វើគុណទៅហើយ បើបានផលអាក្រក់វិញត្រូវតែទទួលការពិសោធន៍ដោយដៃពីរ

- ខុងជឺបានបង្កើតសីលធម៌មួយទៀតហៅថា « ជិន » ប្រែថា « ស្រលាញ់អ្នកដទៃ » ខុងមានបំណងអោយអ្នកសិក្សាស្រលាញ់ផលប្រយោជន៍ និងជីវិតអ្នកដទៃ អោយដូចជារបស់ខ្លួនផងដែរគឺ ថា:

- អំពើណាមួយដែលអ្នកពុំចង់អោយគេធ្វើមកលើរូបអ្នកចូរអ្នកកុំធ្វើអំពើនេះទៅលើអ្នកដទៃ ។

- អំពើណាដែលអ្នកស្រាលាញ់ចង់បានអោយគេធ្វើមកលើរូបអ្នកចូរអ្នកធ្វើអំពើនោះទៅអ្នកដទៃជាមុនសិន ។

- អ្វីដែលអ្នកមិនសប្បាយចិត្តចំពោះអ្នកធំ ធ្វើមកលើរូបអ្នកចូរអ្នកកុំយកវាទៅអនុវត្តលើមនុស្សក្រោមបង្គាប់អ្នក ។

ខុងជឺបានបន្សល់នូវសាវ័ក៦នាក់ ដែលគេហៅថា «ទេព្តាទាំង៦» របស់មជ្ឈមណ្ឌល «ជូ» គឺ :

- សាវ័កមហាញាណទី១ឈ្មោះ : ស៊ីងសាន អ្នកទស្សនវិជ្ជាតំណាងខុងជឺ នៅសម័យក្រោយ ។

- សាវ័កមហាញាណទី២ឈ្មោះ : សឺ លូសុខចិត្តប្រឆាំងនិងឪពុកជា-

www.budinst.gov.kh www.elibraryofcambodia.org

មហាសេដ្ឋីដើម្បីសិស្សខុងជឺ ។

- សាវ័កមហាញាណទី៤ឈ្មោះ សឺ ម៉ានាវ មានកិត្តិនាមជាងគេហើយបានរួចជីវិតពីការប៉ងសំលាប់របស់បទបង្កើតដោយសារខុងជួយសង្គ្រោះ ។

- សាវ័មហាញាណទី៥ គង់យេឆាងជាអ្នកប្រាជ្ញគម្ពីលី ។ គាត់ចេះពិធីការសែនព្រេន និង មានសិល្បៈចេះចាប់ទឹកមុខ ។

- សាវ័កមហាញាណទី៦ ឈ្មោះសួនឈិង ជាអ្នកទោសអស់ជីវិតតែត្រូវបានខុងជួយរំដោះជាផ្លូវនិងប្រស្នា ។

LIBRARY
BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

**មេរៀនទី៨**

# ព្រះយេស៊ូគ្រីស្ទ

សាសនាព្រះយាស៊ូគ្រីស មានដើមកំណើតនៅប្រទេសស៊ីរ ។ ពេលនោះគេដំណាលថា : ព្រះយេស៊ូជាបុត្រារបស់ព្រះអាទិទេពទ្រង់មកចាប់កំណើតជាមនុស្សនៅឋានកណ្តាល ទ្រង់ប្រសូត្តិនៅភូមិ ប៉េថ្លេហិប ស្រុកយូដាក្នុងរាជ្យស្តេច «ហេនុឌ» ប្រទេសអ៊ីស្រាអែលបច្ចុប្បន្ន ។ គេបានថ្វាយព្រះនាមថា : « **ព្រះយេស៊ូទ ឬ អេម៉ាញ៉ូអែល** » ដែលប្រែថា ព្រះអង្គទ្រង់គង់«ជាមួយនឹងយើងខ្ញុំ » ។

នៅពេលពេញវ័យព្រះយេស៊ូបានយាងពីស្រុកមួយទៅស្រុកមួយដើម្បីអប់រំទូន្មានអោយមនុស្សគ្រប់រូបប្រព្រឹត្តតែអំពើល្អ ដើម្បីស្វែងរកឋានសួគ៌ ។ ព្រះអង្គបានជួយសង្គ្រោះដល់ជីវិតមនុស្សជាច្រើន ដូចជាសំដែងនូវអភិនិហារប្រស់មនុស្សដែលស្លាប់៤ថ្ងៃហើយ អោយមានជីវិតរស់ឡើងវិញ ។ ព្រះអង្គបានប្រស់នូវជំងឺទាំងឡាយមាន : ឃ្លង់ - ថ្លង់- គ- ខ្វាក់ខ្វិន រហូតដល់កំហែងខ្យល់ព្យុះអោយស្ងប់. . .។ ព្រះយេស៊ូមានសិស្សជាច្រើន ។ ព្រះអង្គបានប្រស់ឡាស់សា អោយរួចពីសេចក្តីស្លាប់ដោយសារតែមូលហេតុនេះមើយបានជាពួកសង្ឃរាជមានការច្រណែននិន្ទា ហើយក៏បានចោទប្រកាន់មួលបង្កាច់

www.budinst.gov.kh www.elibraryofcambodia.org

ព្រះយេស៊ូវហូតដល់ចាប់ព្រះយេស៊ូយកទៅឆ្កាងដើម្បីសំលាប់ ។ យេស៊ូមានសិស្សជិតស្និទ្ធចំនួន១២នាក់ដែលហៅថា សាវ័កគឺឈ្មោះ ម៉ាថាយ - យ៉ូហាន - ប៉េត្រុស - យូដាស់ - ថូម៉ាស់ - យ៉ាកុប - ហ្វីលីព - បារថូល៉ូម៉េ - យូដាស់អ៊ី ស្ការីយ៉ូត - យ៉ាកុប - ស៊ីម៉ូនអានទ្រេ ។

ក្នុងចំណោមសាវ័កទាំង១២នេះមានឈ្មោះយូដាស់ ២នាក់ យ៉ាកុប ២នាក់ ដែលដូចគ្នា តែឪពុកម្តាយទីទៃ ហើយក្នុងនោះមានសាវ័ករបស់យេស៊ូម្នាក់ ដែលក្បត់ព្រះអង្គគឺ យូដាស់អ៊ីស្ការីយ៉ូត ដែលនាំទាហានមកចាប់ទ្រង់ដោយសារស្រលាញ់អំណាចនិងទឹកប្រាក់ ។

## ឧសរុនជិជ្ជារបស់ព្រះយេស៊ូ

ព្រះយេស៊ូតែងតែប្រៀនប្រដៅទូន្មានដល់មនុស្សទាំងឡាយ អោយប្រព្រឹត្តតែអំពើល្អ មានមនុស្សធម៌ ទើបបានទៅកាន់ឋានសួគ៌ ។ យើងសង្កេតឃើញព្រះបន្ទូលខ្លះរបស់ទ្រង់មានន័យប្រហាក់ប្រហែលនឹងទស្សនៈរបស់ព្រះពុទ្ធខ្លះទៀតប្រហាក់ប្រហែលនឹងខុងជឺ :

- ចូរអ្នកប្រព្រឹត្តតែអំពើល្អចំពោះពួកណាដែលស្អប់អ្នក
- បើគេទះកំភ្លៀងអ្នកខាងស្តាំនោះត្រូវបែរខាងឆ្វេងអោយគេទៀត ។
- បើចង់អោយគេប្រព្រឹត្តនឹងខ្លួនយ៉ាងណា ត្រូវប្រព្រឹត្តនឹងគេបែបនេះ
- បើអោយគេខ្ចីហើយសង្ឃឹមទាររបានវិញ តើនឹងមានគុណបំណាច់

www.budinst.gov.kh www.elibraryofcambodia.org

- កុំថ្កល់ទោសនិន្ទាគេ អ្វីខ្លះ ? ដើម្បីកុំអោយគេនិន្ទាយើងវិញដែរ ។

- គេនឹងវាស់អោយអ្នកតាមរង្វាស់ណាដែលអ្នកវាស់អោយគេ

- ត្រូវឈ្នះអំពើអាក្រក់ដោយសេចក្តីល្អរបស់អ្នក ។

- កុំជំពាក់អ្វីអ្នកណាឡើយ អាចជំពាក់បានត្រឹមសេចក្តីស្រលាញ់

- កុំសំលាប់មនុស្ស កុំលោភ កុំផឹក កុំលួចអោយសោះ ។

- ចូរស្រលាញ់អ្នកជិតខាងដូចស្រលាញ់ខ្លួនឯង ។

- កុំប្រើពាក្យ ស្បថទោះក្នុងឋានសួគ៌ក្តីលើផែនដីក្តី

- កុំសងសឹកឡើយ ។

☸☸☸☸

www.budinst.gov.kh www.elibraryofcambodia.org

# ☪ មូហាម៉ែត

លោកមហាម៉ែតកំពូលទស្សនវិជ្ជា អារ៉ាប់ ។ តាមគម្ពី «កូរ៉ាន់» បាន អះអាងថា : លោកមហាម៉ែតបានចាប់បដិសន្ធិក្នុងឆ្នាំ ៥៧០ នៃគ.ស ។ លោកកើតក្នុងកុលសម្ព័ន្ធមួយឈ្មោះ «កូរ៉ៃជិត» គឺ ត្រកូលដែលជិតជាងគេនៃគ្រួសារ «អ៊ីស្មាអែល» បុត្រនៃអទិទេព «អាប្រាហាម» ។ បិតាឈ្មោះ អេបដាឡាស់ «ជាឈ្មួញម្នាក់នៅទីក្រុង» មេឌីន ដែលតែងតែដឹកនាំគ្រឿងទេស និងវត្ថុដែលមានតំលៃដូចជាត្បូង និងសំពត់ប្លែកៗទៅលក់នៅប្រទេសស៊ីរី ។ មាតាឈ្មោះ «អាមីណា» ជាបទប្អូនរួមត្រកូល និងលោកអេបដាឡាស់ដែរ ។ ក្រោយពេលអេបដាឡាស់ធ្វើមរណកាលទៅនាងអាមីណាក៏វិត្រលប់ទៅនៅជាមួយលោកតា ម៉ូតាលីពជាឪពុកក្មេកនៅទីក្រុងឡាមិចវិញ ។

នៅពេលប្រសូតិលោកមហាម៉ែត គេឃើញមានអព្ភូតហេតុចំលែកអស្ចារ្យរហូតដល់ស្តេច «ម៉ូស្រីស» ចេញបញ្ជាអោយតាមចាប់មហាម៉ែត ។ លោកតា ប៉ូតាលីពបាននាំទារកភៀសខ្លួនទៅសំងំក្នុងវិហារចាស់មួយនៃជនជាតិ «អេចូពី» ដែលជាកុលសម្ព័ន្ធអាហ្វ្រិចភាគតិចរស់នៅវាលខ្សាច់ប្រទេស-

www.budinst.gov.kh www.elibraryofcambodia.org

អារ៉ាប់ ។ លុះអាយុបាន ៦ឆ្នាំ មាតាក៏ធ្វើមរណកាលទៅ មហាម៉ាត់បានរស់នៅជាមួយជីតា ៣ឆ្នាំ ទើបទៅរស់នៅជាមួយឪពុកមាឈ្មោះ អាប៊ូតាលីតជាឈ្មួញដឹកនាំទំនិញទៅលក់នៅប្រទេសស៊ីរី ។ ពេលធ្វើដំណើរតាមផ្លូវមហាម៉ាត់បានជួបនឹងអ្នកបួសគ្រិស្តសាសនាគ្រីស្តម្នាក់ឈ្មោះ « ប៉ាហ៊ីរ៉ា » ។ ប៉ាហ៊ីរ៉ា បានរកឃើញស្លាកស្នាមឆ្អឹងនៅលើខ្នងលោកមហាម៉ាត់ ហើយបានទាយទុកថា « មហាម៉ាត់ថ្ងៃក្រោយនឹងទៅជាអ្នកដឹកនាំមនុស្សទៅរកមាគ៌ាបរិសុទ្ធមួយមិនខាន » ។ អាយុ១៤ឆ្នាំ មហាម៉ាត់បានចូលខ្លួនប្រយុទ្ធជំនួសឪពុកមាដែលជាមេទ័ព ក្នុងសង្គ្រាមជាមួយនឹងអំបូរ « បេនុហាវ៉ាជិន » ។ មហាម៉ាត់បានបញ្ចេញអភិនិហារអោយពួកនោះបាក់ខ្លួនខ្លាច ។ មហាម៉ាត់ក៏មានឈ្មោះល្បីរន្ទឺពីពេលនោះមក ។ មហាម៉ាត់បានរៀបការជាមួយ នាង « ខាឌីយ៉ា» ជាបុត្រីមហាសេដ្ឋីក្នុងអំបូរ « កូរ៉េជិត » បានបុត្រាមួយឈ្មោះ « កាស៊ីម» គេនាំគ្នាហៅមហាម៉ាត់ថា អាប៊ុលកាស៊ីមប្រែថា បិតារបស់កាស៊ីម ។ មិនបានប៉ុន្មានកាស៊ីមក៏ស្លាប់ទៅមហាម៉ាត់បានសុំយកកូនរបស់ឪពុកមាឈ្មោះ «អាលី» មកចិញ្ចឹមរក្សា ។ តាមពិតមានថា មហាម៉ាត់មានភរិយាច្រើនណាស់ ឯបុត្រាបុត្រីក៏ច្រើនដែរ តែស្លាប់អស់នៅសល់តែបុត្រីសំណព្វមួយដែលត្រូវរៀបការជាមួយ «អាលី » ។ នាងហ្វាទីម៉ានេះហើយជាប្រពន្ធរបស់អាលី ។

ខ្សែជីវិតរបស់លោកមហាម៉ាត់ក៏មិនខុសពីសូក្រាតប៉ុន្មានដែរ មហាម៉ាត់ត្រូវអជ្ញាធរនៃក្រុងឡាមិច បានជួលទស្សនវិទូអារ៉ាប់នៅក្រុងមេឌីន ជាគ្រិស្តសាសនាហៅថា រ៉ាប៊ីន មកសួរដេញដោលមហាម៉ាត់ដើម្បីការកែប្រែសាសនា-

www.budinst.gov.kh www.elibraryofcambodia.org

ឧក្រិដ្ឋផ្សេងៗ តែមហាម៉ែតនៅតែឆ្លើយប្រស្នារួច ។ មហាម៉ែតបានគេចខ្លួនទៅនៅរូងភ្នំទីបំផុតគាតក៏សំរេចចិត្តធ្វើសង្គ្រាមក្តៅតបវិញ ។ ដំបូងគាត់វាយកបានក្រុង «មេឌីន» ដោយមានប្រជាជនមុយស៊ុលម៉ង់ គាំទ្រគាត់ ។ នៅទីនោះមហាម៉ែតត្រូវបានមេទ័ពឈ្មោះ ហ៊ីរ៉ូដ លើកនាងហ្វ៊ីណោពអោយធ្វើជាភរិយា ។ មហាម៉ែតបានធ្វើជាមេកុលសម្ព័ន្ធនៅទីក្រុងមេឌីន ។ បន្ទាប់ពីនោះ គាត់បានវាយដណ្តើមទីក្រុងឡាមិចទាំងមូល និង កែប្រែនូវរូបភាពសាសនាគ្រីស្តទាំងឡាយដែលនៅក្នុងវិហារអោយទៅជាសាសនាអ៊ីស្លាមវិញ ។ តាំងពីនោះមកប្រជារាស្ត្រអារ៉ាប់ និង មុយស៊ុលម៉ង់ លើដែនដីទាំងមូល លើកលែងតែពួកជីហ្វខ្លះប៉ុណ្ណោះ បាននាំគ្នាដើរតាមមាគ៌ាលោកមហាម៉ែត្រគ្រប់ៗគ្នា ។ គ្រប់ច្រកល្ហកគេឮតែសំលេងសូត្រធម៌សំលេងទូន្មានបែបទស្សនវិជ្ជានៃគម្ពីរ «កូរ៉ាន់» ។ នៅរាត្រីនៅថ្ងៃទី១៣ រ៉ាប៊ី ដើមឆ្នាំទី១១ អេហ្ស៊ីរបស់អារ៉ាប់ត្រូវនឹងថ្ងៃទី៨ មិថុនា គ.ស ៦៣២ លោកមហាម៉ែតបានលាចាកលោកទៅបានបន្សល់នូវពាក្យទូន្មានសាសនា និងទស្សនវិជ្ជដូចជា :

- កុំលួចទ្រព្យគេ កុំប្រើពាក្យមុសា , កុំសំលាបមនុស្សល្អ
- កុំលួចប្រពន្ធគេ, កុំបរិភោគសាច់ជ្រូក ជាសាច់អោយទោស
- ត្រូវមានយុត្តិធម៌ក្នុងសង្គម និង ក្នុងខ្លួនបុគ្គលម្នាក់ ៗ
- ត្រូវមានអធ្យាស្រ័យដល់ស្ត្រីភេទ « បំបាត់ការលក់ទិញមនុស្ស »

កិច្ចវត្តរបស់មហាម៉ែតក្នុងការកសាងមាគ៌ាបរមសុខគតិ :

១- ការសូត្រធម៌ ឬ សរពាធិ

www.budinst.gov.kh www.elibraryofcambodia.org

២- អត់អាហារនៅថ្ងៃសីល

៣- ការដើរស្វែងរកបិណ្ឌបាទ

៤- ត្រូវធ្វើធម្មយាត្រាទៅក្រុងពិសិដ្ឋគឺ ក្រុងឡាមិចយ៉ាងហោចមួយដង ក្នុងមួយជីវិត ។

៥- ត្រូវផ្សព្វផ្សាយសាសនា ដែលមានចែងក្នុងគម្ពីគូរ៉ាន់ ដោយហ៊ានស្លាប់ ដើម្បីធ្វើពលីកម្មសាសនា ។

អោយគេយល់ខុសពីព្រះពុទ្ធបរមគ្រូ គាត់យល់ថាគ្មាននិព្វានទេ ។ ដោយសារការផ្សាយរបស់មហាម៉ត់ គេសង្កេតឃើញសាសនាអ៊ីស្លាមរីកចំរើន ស្ទើរគ្រប់ប្រទេសផែនដីនៃសកលលោកសូម្បីប្រទេសឥណ្ឌាមួយចំនួន ក៏មានសាសនាឥស្លាមដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

# ហេហ្គែល

១៧៧០ - ១៨៣១

អេហ្គែល ជាទស្សនវិទូអនោនិយមបដិសំយោគ ជាតិអាល្លឺម៉ង់គាត់កើតនៅឆ្នាំ ១៧៧០ នៃ គ.ស ។ ឯកសារពុំបានបញ្ជាក់ទីកន្លែងកំណើត និងឪពុកម្ដាយរបស់គាត់ច្បាស់លាស់ទេ ។ ទស្សនវិជ្ជារបស់លោក គេសង្កេតឃើញមានទំនាស់ក្នុងទស្សនៈវិជ្ជានេះគឺទំនាស់រវាងចរិកអភិរក្សនៃប្រព័ន្ធទស្សនវិជ្ជា និង បដិសំយោគ ។ ក្នុងឋានៈគាត់ជាអ្នកអនោនិយម គាត់យល់ថាអ្វីៗសុទ្ធតែកើតពីគំនិតដែលចេញពីអទិទេព មនុស្សម្នាក់ខ្ពស់អស្ចារ្យដោយសារទស្សនវិជ្ជាដ៏ល្បីល្បាញរបស់គាត់ អេហ្គែលបានក្លាយជាសាស្ត្រាចារ្យផ្នែកទស្សនវិជ្ជានៅសកលវិទ្យាល័យនៃប្រទេសព្រុស នៃប្រទេសអាល្លឺម៉ង់ ។

ចរិកបដិសំយោគ និងទស្សនវិជ្ជារបស់អេហ្គែលចរិកនេះបានសំដែងនៅក្នុងសៀវភៅ «ដំណើរអភិវឌ្ឍន៍នៃចក្រវាឡ» មានន័យថា : គំនិតអទិទេពវិវត្តន៍ចេញពីអទិទេព ចូលទៅក្នុងធម្មជាតិ ហើយទៅរកសង្គមមនុស្ស រួចវិលទៅរកអទិទេពវិញ ។ ដំណើរនេះគាត់អោយឈ្មោះថា «ការបាត់ចរិកផ្លូវផងរបស់គំនិតអទិទេព» ។ គាត់បានប្រើសៀវភៅពាក្យាល ដើម្បីបកស្រាយគំនិតគឺ :

www.budinst.gov.kh www.elibraryofcambodia.org

- ឡូស៊ីចវិទ្យា : និយាយពីប្រព័ន្ធបញ្ញត្តិ និង ប្រភេទឡូស៊ិច

- ទស្សនវិជ្ជាធម្មជាតិ : បញ្ញត្តិបំលែងទៅជាធម្មជាតិ

- ទស្សនវិជ្ជាស្មារតី : ស្មារតីដាច់ខាតចេញពីធម្មជាតិមកក្នុងគំនិតមនុស្ស ។

ទស្សនៈគាត់យល់ថា គំនិតអទិទេពបានប្រាសចាកពីអទិទេពចូលមកក្នុងធម្មជាតិ អទិទេពបានខូចសារជាតិ បាត់បង់ចរិកផ្លូវផង់មួយចំនួន ។ គំនិតឬព្រលឹងនេះចាកចេញពីធម្មជាតិទៅរកសង្គមមនុស្ស ។ នៅពេលចេញផុតពីសង្គមទើបអាចវិលត្រឡប់ទៅរកអទិទេពវិញ ។ នេះជាគំនិតដេលប្រឆាំងនឹងអភិរក្សនិយម ។ គំនិតអភិរក្សរបស់គាត់សំដែងក្នុងស្នាដៃមួយគឺ «បញ្ហារដ្ឋ» គាត់យល់ថា រដ្ឋអំណាចដែលរីកចំរើនប្រកបដោយរបៀបគ្រប់គ្រង់ទំនើបមានយុត្តិធម៌សមភាពត្រឹមត្រូវគឺ រដ្ឋអំណាចនៃប្រទេសព្រុស ។ គំនិតរបស់គាត់គឺចង់រក្សានូវតួរដ្ឋបែបនេះរហូត ។ គាត់ចង់រាំងខ្ទប់នូវរបបសក្តិភូមិព្រុសមិនអោយឈានទៅរករបបមូលធន តែទន្ទឹមនេះគេក៏ឃើញគាត់អួតសរសើរមិនដាច់ពីមាត់ពីចលនាបដិវត្តន៍នាយទុននៅប្រទេសបារាំង ឆ្នាំ ១៧៨៩ ដែរ ។ គាត់ថាបដិវត្តនេះជាបដិវត្តដាច់ខាតជឿនលឿន តែប្រែសង្គមពីថ្នាក់ក្រោមដល់ថ្នាក់លើ ។ ដូច្នេះគាត់មានគំនិតការពាររបស់សក្តិភូមិព្រុសផង ហើយសរសើរបដិវត្តនាយទុនបារាំងផង ។ ដោយសារលក្ខណៈសេដ្ឋកិច្ចនិង សង្គមផង ក្នុងឋានៈគាត់ជាវណ្ណៈអធនគាត់គ្មានចរិតដាច់ខាតឡើយ ។ ទស្សនវិជ្ជា-

www.budinst.gov.kh www.elibraryofcambodia.org

របស់អេហ្គែលជាទស្សនវិជ្ជា អនោនិយមមានតែថ្លាស និង សំបកជាបដិសំយោគ ។ ម៉ាក់និង អង់ហ្គែលបានកែប្រែពិធីបដិសំយោគដាំក្បាលចុះមួយចំនួនរបស់អេហ្គែលអោយឈរត្រង់វិញ ដោយទាត់ចោលចំនុចអភិរក្សខ្លះ ។

ស្នាដៃរបស់អេហ្គែលមាន : ស្មារតីបាតុភតវិទ្យា -ឡូស៊ីចវិទ្យា -ទស្សនវិជ្ជាស្មារតី -ទស្សនវិជ្ជាច្បាប់ -ទស្សនវិជ្ជាស្តីពីប្រវត្តិសាស្ត្រ -ឡូស៊ីចទស្សនវិជ្ជាធម្មជាតិ -ទស្សនវិជ្ជាស្តីសិល្បៈវិទ្យា . . . ។



www.budinst.gov.kh www.elibraryofcambodia.org

មេរៀនទី១១

# កាលម៉ាក្ស

១៨១៨ - ១៨៨៣

កាលម៉ាជាជនជាតិអាល្លឺម៉ង់ កើតនៅទីក្រុងទ្រៀរខេត្តរីននៃប្រទេសព្រុស ។ កើតនៅថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ១៨១៨ ក្នុងគ្រួសារមេធាវីឪពុកឈ្មោះ ហេ្គរីហ៍ ។ នៅពេលសិក្សានៅសកលវិទ្យាល័យនៅទីក្រុងបោន បន្ទាប់មកនៅក្រុងប៊ែរឡាំង ម៉ាក្ស បានសិក្សាប្រវត្តិសាស្ត្រអក្សរសិល្ប៍ -ទស្សនវិជ្ជា -និតិសាស្ត្រ យ៉ាងជ្រៅជ្រះ ។ ម៉ាក្សបានរៀបការជាមួយនឹងនាង «ហ្សេនីវ៉ុន វេស្តហ្វាលេន»។ នៅឆ្នាំ១៨៤៤ នៅទីក្រុង ប៉ារីស ម៉ាក្សបានជួប ហ្វ អង់ហ្គែល ជាលើកដំបូងនៅពេលបានអាយុ ២៦ឆ្នាំ ម៉ាក្សបានបង្កើតទស្សនៈថ្មីៗ ជាទស្សនៈវិទ្យាសាស្ត្រពិតប្រាកដស្តីពីពិភពលោក ស្តីពីជីវភពសង្គម ។ នៅឆ្នាំ ១៨៤៩ ម៉ាក្សត្រូវបង្ខំចិត្តចេញទៅនៅទីក្រុងឡុងដ៍ ដែលជាទីដែលគាត់រស់នៅរហូតដល់ថ្ងៃស្លាប់ ។ ស្ថានភាពរស់នៅរបស់ម៉ាក្ស លំបាកវេទនា ស្ទើរតែរកប្រាក់ទិញនំប៉័ងហូបមិនបាន តែបានជំនួយឧបត្ថម្ភពីអង់ហ្គែល ។ ទោះបីជាលំបាកទ័លក្រ យ៉ាងណាក៏ដោយក៏ម៉ាក្ស នៅតែបំពេញសកម្មភាព វិទ្យាសាស្ត្រ និង បដិវត្តយ៉ាងសកម្ម គាត់ធ្វើការស្រាវជ្រាវ អស់រយៈពេល ៤០ឆ្នាំ ដើម្បីបង្កើតវណ្ណកម្មមូលធន ។

www.budinst.gov.kh www.elibraryofcambodia.org

នៅថ្ងៃទី ១៤ ខែមិនា ឆ្នាំ ១៨៨៣ កាល់ម៉ាក្សបានទទួលមរណភាព ដោយបានបន្សល់ទុកនូវស្នាដៃជាច្រើន ។

## ទស្សនវិជ្ជារបស់កាល់ម៉ាក្ស

កាល់ម៉ាក្សជាអ្នកទស្សនវិជ្ជាផ្នែករូបធាតុនិយម ជាអ្នកបង្កើតនូវលទ្ធិសំភារៈនិយមវិចារវិទ្យា និង លទ្ធិសំភារៈនិយមប្រវត្តិសាស្ត្រ ។

ម៉ាក្សបានកំណត់ថា : រូបធាតុមានមុនញាណ ពិភពលោកមានតែមួយគត់ គឺពិភពរូបធាតុហើយ ហើយពិភពលោកនោះអត្ថិភាពជាបរានុម័ត មិនចំណុះញាណរបស់មនុស្ស គឺឯករាជ្យពីមនសិការរបស់មនុស្ស ឯមនសិការមនុស្សគឺជាការឆ្លុះបញ្ចាំងរបស់ពិភពលោកនោះទៅក្នុងខួរក្បាលរបស់មនុស្សយើង ។ មនុស្សកើតហើយកែងស្លាប់ទៅវិញជាធម្មតា តាមក្រិត្យក្រមរបស់ធម្មជាតិគ្មានអទិទេពណាបង្កើតហើយបំផ្លាញនោះទេ ។

មនុស្សអាចយល់ដឹងនិងកែប្រែពិភពលោកបាន មិនមែនអទិទេពទេ។ ម៉ាក្សបានចែកបាតុភូតជាពីរគឺ :

- បាតុភូតធម្មជាតិ : ភ្លៀង ផ្គរ រន្ទះ ព្យុះ. . .
- បាតុភូត សង្គម : ការជិះជាន់វណ្ណៈ សង្គ្រាម. . . .

ដូច្នេះត្រូវហ៊ានប្រឆាំង នឹងអំពើជិះជាន់លើមនុស្សដូចគ្នាគ្មានអទិទេពណាកំនត់វាសនាមនុស្សទេ គ្មានអទិទេពណាបង្កើតមនុស្សទេ ផ្ទុយទៅ

www.budinst.gov.kh www.elibraryofcambodia.org

ទៅវិញមនុស្សទេដែលបង្កើតអទិទេព ។ មនុស្សចេះកែប្រែ និង ច្នៃធម្មជាតិ យកមកបំរើផលប្រយោជន៍មនុស្សតាសទំលាយនូវអាថិកំបាំងរបស់ចក្រវាឡគឺៈ មនុស្សអាចបំបាត់រន្ទះ -ធ្វើម្ចាស់លើគង្គា -បង្កើតភ្លៀង -សិប្បនិម្មិត -បំបែកពពកអាប់បង្កើតយានអវកាសទៅឋានព្រះច័ន្ទ .... ។

ទស្សនវិជ្ជាម៉ាក្សជាទស្សនៈពឹងផ្អែកទាំងស្រុងលើវិទ្យាសាស្ត្រ បដិសេធភាពជំនឿសាសនា ដែលយល់ដោយពួកស្រមើស្រមៃឥតបានការ ។




**សេវាទាន់ចិត្ត**



**ផ្ទះលេខ ១៩ ផ្លូវលេខ ១៩**

**ទល់មុខវត្តសារាវ័នតេជោ**

**វាយកុំព្យូទ័រដោយ : ឯល សារីហ៊ុន**


www.budinst.gov.kh www.elibraryofcambodia.org

# ហ្សង់ប៉ូសាត

# JEAN. PAUL SARTRE

ហ្សង់ប៉ូសាតកើតនៅឆ្នាំ ១៩០៥ នាក្រុងប៉ារីស ហើយត្រូវកំព្រាឪពុកតាំងពីកើតមក លោកបានប្រឡងចូលសាលាគរុវិជ្ជា ជាន់ខ្ពស់នៅឆ្នាំ ១៩២៥ ។ នៅឆ្នាំ ១៩២៨លោកបានប្រលងជាប់លេខ ២១ ផ្នែកមហាបរិញ្ញប័ត្រទស្សនវិជ្ជា លោកបានបង្រៀននៅខេត្តរហូតមកដល់ទីក្រុងប៉ារីស ។ ពេលនោះហើយដែលលោកផ្ដើមសរសេរសៀវភៅដូចជា : សៀវភៅទី១ ឈ្មោះថា LAWAUSEE ប្រែថា «កំអួតសង្គម» ព្រមទាំងស្នាដៃផ្សេងៗជាច្រើនទៀត។ ស្នាដៃរបស់លោក ច្រើនរិះគន់សង្គម ហើយអប់រំបុគ្គលម្នាក់ៗ អោយយល់ច្បាស់ពីខ្លួនឯង ។

## ទស្សនវិជ្ជារបស់ហ្សង់ប៉ូលសាត

ចលនាគំនិតរបស់ប៉ូលសាត មានប្រភពចេញពីប្រទេសជាតិឆ្លងកាត់សង្គ្រាមយ៉ាងសាហាវ បណ្ដាលអោយជីវភាពប្រជាពលរដ្ឋវេទនា ឯអ្នកគិតកែសន្ទុំទ្រព្យហើយឃោសនាអោយតំលៃលើវិទ្យាសាស្ត្រ មនុស្សមួយពួកទៀតរិលវល់ក្នុងទ្រឹស្ដីវិចារនិយម ដែលលោកប៉ែរសុនបានប្រឆាំងម្ដងរួចមកហើយ ។ លោកចាប់ផ្ដើមពិចារណាពីស្ថានភាពមនុស្សពោលគឺការរស់នៅនា-

www.budinst.gov.kh www.elibraryofcambodia.org

បច្ចុប្បន្ន ដែលសាតអោយឈ្មោះថា Existence ហើយក៏ចាប់ផ្ដើមបង្កើតប្រព័ន្ធទស្សនវិជ្ជាមួយអោយឈ្មោះថា «អត្ថិភាព» ។ សព្វថ្ងៃនេះគេបានបញ្ចូលប្រព័ន្ធទស្សនវិជ្ជាឥតន័យនិយមរបស់កាមុស ចូលក្នុងចលនា «រស់និយម» របស់សាត ដោយហេតុចលោនា គំនិតទាំងពីរនេះប្រឆាំងនឹងការរស់នៅរបស់សង្គមពុំប្រកបដោយសីលធម៌ ។ ម្នាក់ៗខិតខំរិះរកមធ្យោបាយបង្កើតទ្រព្យសម្បត្តិ ដោយកសាងសេចក្ដីសុខលើគំនរទុក្ខអ្នកដទៃ ។ សាតប្រឆាំងនឹងសង្គមតាមទ្រឹស្ដី ។

មានន័យថា : ការរស់នៅប្រសើរជាងអ្វីៗ ដែលខ្ពស់ខ្ពស់ ។ មនុស្សមនិត្រូវប្រាថ្នាអ្វីដែលខ្ពស់ពេកទេ ត្រូវគិតត្រឹមតែការរស់នៅរបស់ខ្លួនបានហើយ ។ លោកសាតរិះគន់យ៉ាងខ្លាំងនូវទស្សនៈរបស់កាមុស ហើយចោទប្រកាន់កាមុសថាជាអ្នកយល់បញ្ហាសង្គមតាមទស្សនវិជ្ជា «រស់និយម» ដែរ ប៉ុន្តែកាមុសបែរជាសរសើររឿងបុគ្គលដោយយកបុគ្គលម្នាក់តំណាងសង្គម ។

ជនចំណែកម្នាក់មិនចុះសំរុងនឹងជីវិត ។ សាតយល់ថា : «មនុស្សគឺជាអំពើរបស់ខ្លួន» គេបានធ្វើអំពើអ្វីមួយនោះជាលក្ខណៈរបស់គេ មិនអាចលុបបាន ។ មនុស្សកើតមកគ្មានន័យភ្លាមទេលុះត្រាផ្ដើមធ្វើអ្វីមួយទើបអាចរកលក្ខណៈរបស់គេបានគឺ លក្ខណៈបានមកពីសកម្មភាព និង អំពើរបស់គេ ។ មនុស្សត្រូវតែធ្វើដំណើរទៅរកអនាគតគតិ សេរីភាពនៃការបង្កើតអនាគត ។

សតជាមនុស្សសុទិដ្ឋិនិយមព្រោះគាត់អប់រំមនុស្សអោយមានឧត្តមគតិ ប្រយុទ្ធដើម្បីរស់នៅឆាកជីវិតរបស់ខ្លួនទៅទៀត ។

www.budinst.gov.kh www.elibraryofcambodia.org

# អាល់ប៊ែរកាមុស

## ALBERT-CAMUS

## ១៩១៣ - ១៩៦០

លោក កមុសជាជនជាតិបារាំង កើតនៅអាល់ហ្សេរីថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ១៩១៣ ។ ឪពុកឈ្មោះ លុស្យាងកាមុសម្តាយឈ្មោះការីកវីសាំងហ្គែល ។ នៅពេលអាយុ១ឆ្នាំ កាមុសត្រូវកំព្រាឪពុកក្នុងសង្គ្រាមលោកលើកទី១ ។ កាមុសរស់នៅក្នុងទុរគតភាពជាមួយម្តាយ ។ ដោយការខិតខំស្វិប្រឹងប្រែងពេកបានប្រលងជាប់សញ្ញាប័ត្រធម្មមសិក្សាហើយបន្តការសិក្សាផ្នែកទស្សនៈវិជ្ជារហូតដល់បានសញ្ញាប័ត្រវិជ្ជាជាន់ខ្ពស់បំផុត ប៉ុន្តែត្រូវអាក់ខានពុំបានប្រលងសញ្ញាប័ត្រសាស្រ្តាចារ្យមធ្យមសិក្សាផ្នែកទស្សនវិជ្ជា។នៅឆ្នាំ១៩៣០ លោកត្រូវកើតជំងឺរបេង ។ ក្នុងឆាកជីវិតរបស់គាត់គឺចូលចិត្តចូលចិត្តដើរកំសាន្តច្រើន ចូលពន្លឺព្រះអាទិត្យនិងសមុទ្រ ។

អាល់ប៊ែរកាមុសស្លាប់នៅថ្ងៃ ២៤ ខែ គុម្ភៈ ឆ្នាំ ១៩៦០ វេលាម៉ោង ១៣ និង ៤៥ នាទី ដោយបើករថយន្តទៅមុកដើមឈើ ។

***ទស្សនវិជ្ជារបស់អាល់ប៊ែរកាមុស:**

កាមុសជាអ្នកចូលចិត្តល្ខោន ។ លោកជាអ្នកនិពន្ធរឿងល្ខោន-

www.budinst.gov.kh www.elibraryofcambodia.org

លោកបានបង្កើតក្រុមល្ខោនឈ្មោះ «អេតឺព» ។ ក្រៅពីនេះលោកជាអ្នកនិពន្ធសារពត៌មាន ។ ស្នាដៃរបស់លោកជាជ្រើសធ្វើអោយសាធារណជនពេញចិត្ត និង ចាប់អារម្មណ៍ ។ លោកបានទទួលរង្វាន់ណូបែលឆ្នាំ ១៩៥៧ គឺរឿង «មិនចុះសំរុងនឹងជីវិត» ។

កាមុសយល់ថា :

សុភមង្គលរបស់មនុស្សពុំមែនស្ថិតនៅក្នុងឧត្តមគតិទេ បើមានមែននោះគឺជាសុមង្គលដែលចេញពីការរស់នៅធម្មតាភ្លាមៗហើយ ដែលគ្មានការទាក់ទងនឹងគំនិតឬឧត្តមគតិអ្វីទាំងអស់ គឺការសប្បាយបន្តិចបន្តួចដែលឃ្លាតចេញពីតក្កវិជ្ជាផ្សេងៗ ឬ ចរិយាធម៌ដែលចេញពីតក្កវិជ្ជានោះ ។ សោកនាដ្យកម្មទាំងឡាយច្រើនចេញពីទំនាស់ ។ ភាសាដែលមនុស្សប្រើសព្វថ្ងៃជាមូលដ្ឋាននិងជាប្រភពនៃសោកនាដ្យកម្មដែរ ព្រោះភាសានេះជាភាសាភូតកុហក ដែលធ្វើអោយពិភពលោក ប្រាសចាកពីការពិត ។

កាមុសបានរិះគន់យ៉ាងខ្លាំង ចំពោះចលនាបដិវត្តន៍ដែលមានលក្ខណៈផ្តាច់ការ គឺ បង្កើតអោយមានការបង្ហូរឈាមរវាងមនុស្ស និង មនុស្ស លោកបានអះអាងថា : មនុស្សលោក មានលក្ខណៈជាមនុស្សដែលមានទោស ដែលធ្វើដំណើរគ្មានស្រាកស្រាន្តទៅរកភពបរិសុទ្ធ ដែលគ្មានទាល់តែសោះ នៅលើចក្រវាឡ នៃការក្តីរវាង ។ នៅក្នុងសិក្សាកថារបស់លោកមួយឈ្មោះ «មនុស្សប្រឆាំងក្នុងផ្លូវចិត្ត» បានធ្វើអោយមានការខ្វែងគំនិតមួយយ៉ាងសំខាន់

www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងមជ្ឈដ្ឋានអ្នកអក្សរសាស្ត្រជាពិសេសរវាងលោក ហ្សង់ប៉ូលសាត ដែលបានរិះគន់យ៉ាងខ្លាំងទៅគំនិតរបស់កាមុស ដែលពុំព្រមជឿទៅលើបដិវត្តន៍មួយ ។ លោកយល់ថា អាចមានគំនិតផ្តាច់ការ និយមហួសហេតុ ប្រសិនបើបដិវត្តន៍ពុំព្រមទាត់ចោលនូវលក្ខណៈបង្ហូរឈាមឥតន័យទេ ។ លោកសុខចិត្តត្រឹមប្រឆាំងក្នុងគោលគំនិតប៉ុណ្ណោះ ។

គោលគំនិតចំបងរបស់កាមុស ស្ថិតនៅក្នុងរូបមន្ត «ជីវិតនិយម» ដូចតទៅនេះ

មនុស្សយើងមិនគួរសំលាប់ ឬ ស្លាប់ដើម្បីបង្កើតអទិទេពឬវីរបុរសឡើយ ។ គឺគួរតែស្ថិតនៅនិង អនុញ្ញាតិអោយគេរស់នៅក្នុងឆាកជីវិត គ្មានការសមហេតុសមផលមែន ប៉ុន្តែពុំមែនបានសេចក្តីថា : ត្រូវតែគេចវះ អោយផុតតែម្តងនោះទេ ឬក៏ត្រូវទៅពឹងផ្អែកលើអទិទេព ឬ លើជំនឿដែលរិតតែមិនសមហេតុសមផលទៅទៀតនោះ ។ ម៉្យាងទៀតគាត់យល់ថា បើមនុស្សលោកគេចមិនផុតពីការស្លាប់ទេ គួរតែទុកជីវិត តាមសមត្ថភាពដែលខ្លួនអាចធ្វើទៅកើត។

ទោះបីលោកជាបញ្ញវន្តឆ្វេងនិយមក៏ដោយក៏គំនិតរបស់លោកបានត្រូវអ្នកឆ្វេងនិយម ឯទៀតដូចជាហ្សង់ប៉ូសាតជាដើមរិះគន់យ៉ាងខ្លាំង ។ ប៉ុន្តែទីបំផុតគេក៏ទុកលោកមួយឡែកដោយចាក់ទាក់ជាទស្សនវិទូ ឯករងម្នាក់ពោរពេញទៅដោយគំនិតថ្លៃថ្នូ ។

www.budinst.gov.kh www.elibraryofcambodia.org

# សេខា ធានចិត្ត

ភាយកុំព្យូទ័រដោយ : ខុន ណារាឡុង

បោះពុម្ពដោយ : គីន ម៉ុនថន

មានលក់ដុំ និង លក់រាយ

តូបលេខ២៥ ផ្សារអូរឬស្សី

តូបលេខ ៦៤ ផ្សារថ្មី

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាគមន៍ជានិច្ច

ឲឲឲឲឲ

## មានលក់ដុំ និង លក់រាយនូវ ៖

- សៀវភៅអានគ្រប់មុខវិជ្ជា
- ចំរៀងខារ៉ាអូខេ
- រឿងផ្សេងៗ
- រូបភាព , ធម៌ ៤ ល ៤

១- តូបលេខ 25 (ផ្សារអូរឫស្សីថ្មី)

H.P : 018 814 225

២- តូបលេខ 64 (ផ្សារថ្មី)

H.P : 018 815 693

អរគុណ


www.budinst.gov.kh www.elibraryofcambodia.org